ថ្ងៃទី26 ខែមិថុនា ឆ្នាំរេយវ៉ា 2(ឆ្នាំ2020)
(ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 16 ខែមេសា ឆ្នាំ 2021)
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

**ចំពោះអ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅអចិន្ត្រៃយ៍ ដែលមានការពិបាកនឹងចូលមកប្រទេសជប៉ុនក្នុងកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញនៅមានសុពលភាព ដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩** (ក្រោយថ្ងៃទី16 ខែមេសា ឆ្នាំ2021)

ដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩ អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅអចិន្ត្រៃយ៍ដែលមានការពិបាកនឹងចូលមកប្រទេសជប៉ុនវិញ ក្នុងកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញ ឬកម្លុងពេលដែលចាត់ទុកថាមានការអនុញ្ញាតឱ្យចូលវិញនៅមានសុពលភាព អាចចូលមកប្រទេសជប៉ុនវិញបានតាមវិធីខាងក្រោមនេះ (※1) ដូច្នេះ សូមអញ្ជើញទៅពិគ្រោះនឹងស្ថានទូត ឬកុងស៊ុលជប៉ុននៅកន្លែងដែលលោកអ្នករស់នៅ។

(1) ករណីដែលកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញអស់សុពលភាព ឬក្នុងករណីដែលមានការពិបាកនឹងចូលមកវិញក្នុងកម្លុងពេលមានសុពលភាព

មានករណីដែលអាចសុំពន្យារកម្លុងពេលសុពលភាពនៃការចូលមកវិញបាន នៅតាមស្ថានទូត ឬកុងស៊ុលជប៉ុននៅកន្លែងដែលលោកអ្នករស់នៅបាន។

[ កម្លុងពេលដែលអាចពន្យារបានគឺ យ៉ាងវែង 1ឆ្នាំ ដោយគិតពីថ្ងៃដែលកម្លុងពេលមានសុពលភាពបានដាច់។ ]

ក្នុងករណីដែលកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញមានសុពលភាពត្រូវបានពន្យារ សូមចូលប្រទេសជប៉ុនវិញក្នុងកម្លុងពេលពន្យារថ្មីនោះ។ បើសិនជាមិនអាចពន្យារបាន សូមចូលមកវិញដោយវិធីទី(2) ។

(2) ករណីដែលកម្លុងពេលដែលចាត់ទុកថាមានការអនុញ្ញាតឱ្យចូលវិញមានសុពលភាពបានកន្លងផុត (រួមទាំងករណីដែលមិនអាចធ្វើតាមចំណុច(1)បាន)

[ អ្នកដែលកម្លុងពេលដែលការអនុញ្ញាតឱ្យចូលវិញមានសុពលភាព ឬកម្លុងពេលដែលចាត់ទុកថាការអនុញ្ញាតឱ្យចូលវិញមានសុពលភាព បានដាច់ក្រោយ ថ្ងៃទី 1 ខែមករា ឆ្នាំ2020 ហើយក្នុងកម្លុងពេលពី 6ខែក្រោយថ្ងៃដែលបានលុបចោលនូវការកម្រិតការចូលប្រទេសជប៉ុន (※2) រហូតដល់ ]
កាលបរិច្ឆេទដែលត្រូវកំណត់ ដោយឡែកដោយទីភ្នាក់ងារ(※3)គឺជាមុខសញ្ញា។(※4)

សូមអញ្ជើញទៅដាក់ពាក្យសុំទិដ្ឋាការ "អ្នកស្នាក់នៅជាប់លាប់" នៅស្ថានទូត ឬស្ថានកុងស៊ុនជប៉ុននៅកន្លែងរស់នៅរបស់អ្នក ក្នុងកម្លុងពេល 6ខែក្រោយពីថ្ងៃដែលការកម្រិតការចូលមកជប៉ុនត្រូវបានលុបចោល រហូតដល់កាលបរិច្ឆេទដែលត្រូវកំណត់ ដោយឡែកដោយទីភ្នាក់ងារ។

ពេលដែលបានទទួលទិដ្ឋាការហើយ អាចធ្វើនីតិវិធីចូលប្រទេសជប៉ុនជាថ្មី ក្នុងនាមជា "អ្នកស្នាក់នៅអចិន្ត្រៃយ៍" នៅតាមអាកាសយានដ្ឋានជប៉ុនបាន។

※1 ទោះជាអ្នកដែលជាមុខសញ្ញានៃការចាត់វិធានការនេះក៏ដោយ តែបើសិនជាអ្នកនោះស្នាក់នៅប្រទេស ឬតំបន់ដែលការកម្រិតការចូលប្រទេសជប៉ុនមិនទាន់ត្រូវបានលុបចោលទេ ក៏មិនអាចចូលប្រទេសជប៉ុនបានដែរ លើកលែងតែមានការអនុញ្ញាតដោយសារមានស្ថានភាពពិសេសណាមួយ។

※2 ថ្ងៃដែលការកម្រិតការចូលប្រទេសជប៉ុនត្រូវបានលុបចោល គឺជាថ្ងៃដែលបានលុបចោលនូវការបដិសេធមិនឱ្យចូលប្រទេសជប៉ុនពីប្រទេស ឬតំបន់ដែលកំពុងស្នាក់នៅ ឬថ្ងៃដែលបានលុបចោលនូវការបង្អាកអានុភាពនៃទិដ្ឋាការដែលបានចេញហើយ។
ស្តីពីស្ថានភាពនៃការកម្រិតការចូលប្រទេសជប៉ុនចំពោះប្រទេស ឬតំបន់ សូមមើលគេហទំព័ររបស់ក្រសួងយុត្តិធម៌ខាងក្រោមនេះ។

http://www.moj.go.jp/isa/content/930005848.pdf

※3 «កាលបរិច្ឆេទដែលត្រូវកំណត់ ដោយឡែកដោយទីភ្នាក់ងារ» នឹងត្រូវប្រកាសនៅលើគេហទំព័ររបស់ទីភ្នាក់ងារ។ល។ប្រហែល 3ខែមុន។

※4 ស្តីពីវិសាលភាពនៃកម្លុងពេលមានសុពលភាពនៃការអនុញ្ញាតឱ្យចូលវិញ ដែលជាកម្មវត្ថុនេះ សូមមើលកន្លែងនេះ។ ក្រោយពីថ្ងៃដែលការកម្រិតការចូលមកជប៉ុនត្រូវបានលុបចោល អ្នកនៅតែអាចចូលប្រទេសជប៉ុនបាន រហូតដល់កាលបរិច្ឆេទដែលត្រូវកំណត់ ដោយឡែកដោយទីភ្នាក់ងារ។ (នៅថ្ងៃទី16 ខែមេសា ឆ្នាំ2021 កម្លុងពេលដែលជាកម្មវត្ថុនេះ ត្រូវបានពន្យារ។)

※5 ស្តីពីឯកសារដែលចាំបាច់ក្នុងការធ្វើនីតិវិធីនៃ (1) និង (2) សូមមើលគេហទំព័ររបស់ក្រសួងការបរទេសខាងក្រោមនេះ។

https://www.mofa.go.jp/about/emb_cons/mofaserv.html

※6 ចំពោះអ្នកដែលជាមុខសញ្ញានៃវិធានការនេះ តែអ្នកនោះមិនប្រើវិធានការនេះ ហើយបានចូលមកប្រទេសជប៉ុនដោយមានលក្ខណៈសម្បត្តិក្រៅពី "អ្នកស្នាក់នៅអចិន្ត្រៃយ៍" ក្នុងកម្លុងពេល ចាប់ពី6ខែក្រោយដែលការកម្រិតការចូលមកជប៉ុនត្រូវបានលុបចោល រហូតដល់កាលបរិច្ឆេទដែលត្រូវកំណត់ ដោយឡែកដោយទីភ្នាក់ងារ ហើយបើសិនជាអ្នកនោះដាក់ពាក្យសុំការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍ក្នុងកម្លុងពេល 6ខែ ក្រោយពីបានចូលមកដល់ជប៉ុន ដោយមានពាក្យសុំការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍  សំណូមពាក្យ (ទម្រង់យោងឧបសម្ព័ន្ធទី1) ឯកសារចម្លងនៃប័ណ្ណស្នាក់នៅពីមុន (ឯកសារកូពី) យើងខ្ញុំនឹងពិនិត្យសំណូមពាក្យនោះ។ (អាចមានករណីដែលទាមទារឱ្យដាក់ឯកសារផ្សេងទៀត)។

ក្នុងករណីដែលបានដាក់ពាក្យសុំការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍ក្រោយពេល 6ខែ បន្ទាប់ពីបានចូលប្រទេសជប៉ុន ចាំបាច់ត្រូវដាក់សំណូមពាក្យសុំការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍ធម្មតា និងឯកសារបញ្ជាក់ដូចគ្នាដែរ ដូច្នេះសូមប្រយ័ត្ន។

ម្យ៉ាងទៀត អ្នកដែលបានក្លាយទៅជាអ្នកស្នាក់នៅរយៈពេលវែងឬមធ្យមតាមរយៈការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍ សូមអញ្ជើញទៅប្រកាសនៅសាលាក្រុង ស្រុក ឃុំ ភូមិនៃលំនៅដ្ឋានរបស់លោកអ្នក ក្រោយពេលទទួលការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍។